# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចកែសម្រួលលើកទី២
## លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០៩១ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤
## សម្រាប់លោក ស៊ុន ពៅ
## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងឯកសារអាជ្ញាប័ណ្ណរួមលេខ ០៩១ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក ស៊ុន ពៅ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤
- យោងលិខិតស្នើសុំពង្រីកតំបន់ចែកចាយរបស់លោក ស៊ុន ពៅ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៧ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧
- យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ១២០ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨

## សម្រេច

### ប្រការ១

កែសម្រួលឯកសារអាជ្ញាប័ណ្ណរួមលេខ ០៩១ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ ដែលបានផ្តល់ជូនលោក **ស៊ុន ពៅ** (បន្ទាប់ពីនេះហៅថា **"អ្នកកាន់ អាជ្ញាប័ណ្ណ"**) សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំព្រែកខ្ពប ឃុំព្រែកហ្លួង និងឃុំ ព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដើម្បីអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីក តំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ (មានបង្ហាញក្នុងផែនទីភ្ជាប់លេខ 091LD-map-Sun Pov-Revised-1-2008 ) ។

### ប្រការ២

ឧបសម្ព័ន្ធទី១ចាស់ នៃឯកសារអាជ្ញាប័ណ្ណលេខ ០៩១ ឯអ ត្រូវជំនួសដោយ ឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។

**ប្រការ៣**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណ លេខ ០៩១ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៤**

សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ត្រូវក្លាយជាផ្នែក មួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៩១ ឯអ ។

**ប្រការ៥**

សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែង ដែលឯកសារអាជ្ញាប័ណ្ណលេខ ០៩១ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ ០៩១ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

**ឧបសម្ព័ន្ធទី១**

**តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី**

**ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**

**លើកទី ១២០ នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨**

១- តំបន់អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺនៅឃុំព្រែកខ្ពប ឃុំព្រែកហ្លួង និងឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ " ផែនទីកំណត់ព្រំ ប្រទល់លេខ 091LD-map-Sun Pov-Revised-1-2008 "ដែលភ្ជាប់មក ជាមួយ ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំពង្រីកតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការ កំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសំរេចអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១ នេះត្រូវធ្វើការកែសំរួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកតំបន់ចែកចាយនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។